**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតវិទ្យាស្ថានវ៉ាន់ដា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើតនិងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំ រេ ច

**មាត្រា ១ :** អនុញ្ញាតអោយបង្កើតវិទ្យាស្ថានឯកជនមួយ ដែលមានឈ្មោះថា " **វិទ្យាស្ថានវ៉ាន់ដា** " (Vanda Institute) ហៅកាត់ថា "វ.វ.ដ" ។ វិទ្យាស្ថាននេះ មានទីតាំងនៅអាគារលេខ ២១៦-២១៨ ផ្លូវម៉ៅសេងទុង សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២:** វិទ្យាស្ថានវ៉ាន់ដា ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រគណនេយ្យ ដែលមានរយៈពេលសិក្សា ៤ ឆ្នាំ ។ ក្នុងពេលអនាគត វិទ្យាស្ថានវ៉ាន់ដា អាចបើកវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ឬ ជំនាញឯកទេសផ្សេងៗ ឬ បង្កើតសាខារបស់វិទ្យាស្ថាន ស្របតាមការរីកចំរើន ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៣: មជ្ឈមណ្ឌលវ៉ាន់ដាគណនេយ្យ ត្រូវបានបញ្ចូលទៅក្នុងរចនាសម្ព័ន្ធវិទ្យាស្ថាន ។

មាត្រា ៤: លក្ខខណ្ឌទទួលសិស្សចូលរៀន :

- បេក្ខជនទាំងពីរភេទ ជាសិស្ស និស្សិត ប្រជាពលរដ្ឋ និង មន្ត្រីរាជការ ។
- បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- បេក្ខជនត្រូវឆ្លងកាត់ការប្រលងតេស្ត ។

មាត្រា ៥: នាយកវិទ្យាស្ថានវ៉ាន់ដា មានភារកិច្ច :

- ជ្រើសរើស សិស្សអោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន ។
- គ្រប់គ្រងអោយបានល្អ នូវការបង្រៀន ការស្រាវជ្រាវ ឯកសារសិក្សា ការប្រលងនិងប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សាជូនក្រសួងអប់រំ យុវជន និង កីឡា រៀងរាល់ឆមាស ។

មាត្រា ៦: វិទ្យាស្ថាននេះ មានក្រុមប្រឹក្សាភិបាលមួយទទួលបន្ទុកគ្រប់គ្រងវិទ្យាស្ថាន និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ ដែលមានសមាជិកយ៉ាងតិច ០៣ រូប និងមានសញ្ញាប័ត្រម៉ាស្ទ័រយ៉ាងទាប ក្នុងមុខជំនាញនីមួយៗ សំរាប់ពិនិត្យ និងផ្តល់ការយល់ព្រមលើកម្មវិធីសិក្សា នៅដើមឆ្នាំសិក្សានីមួយៗ ។

មាត្រា ៧: ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ច និងត្រួតពិនិត្យលើការងារបណ្តុះបណ្តាល ហើយមានសិទ្ធិស្នើសុំបិទ ប្រសិនបើវិទ្យាស្ថាននេះ អនុវត្តខុសពីច្បាប់រដ្ឋ ។

មាត្រា ៨: និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវបានទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ "វិទ្យាសាស្ត្រគណនេយ្យ" ដែលផ្តល់អោយដោយ វិទ្យាស្ថានវ៉ាន់ដា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញនិងអនុវត្តតាមនិយាមអប្បបរមា នៃការទទួលស្គាល់គុណភាពអប់រំថ្នាក់ឧត្តមសិក្សា ។

មាត្រា ៩: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលរាជធានីភ្នំពេញ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងវិទ្យាស្ថានវ៉ាន់ដា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*ចំលងជូន :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៩*
- *ឯកសារ-កាលប្បវត្តិ*